ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល
ជាតិ សាសនា ព្រះមហាក្សត្រ

សភា រដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី

លេខ : ១៦៥

ចុះថ្ងៃទី០៥ខែមិថុនាឆ្នាំ១៩៩៨

សាលដីកា

លេខ : ៧៦

ចុះថ្ងៃទី២២ខែមេសាឆ្នាំ១៩៩៩

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៩៩ ដោយមានសមាសភាពដូចតទៅ :-

១- ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២- លោក ម៉ែន ស៊ិន ជាចៅក្រម

៣- លោក វេរៀល មួន ជាចៅក្រម

៤- លោក ជីវ កេង ជាចៅក្រម

៥- លោក ស៊ិន ឌឹម ជាចៅក្រម

ក្រឡាបញ្ជី

កញ្ញា សេន សុខា

តំណាងមហាអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ៧៣៣ ចុះថ្ងៃទី ០៨.១២.៩៧ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៣៩៤ ចុះថ្ងៃទី ០២.៧.៩៧ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះនាង សុខ ខេង អាយុ ៣៧ ឆ្នាំ ជាតិ ខ្មែរ មុខរបរ នៅផ្ទះ ទីលំនៅពុ ក្រុម ២ ភូមិ រតនៈ ឃុំ រតនៈ ស្រុក ស្វាយទៀ ខេត្ត បាត់ដំបង ។ ឪពុកឈ្មោះ ស៊ឹម ហ៊ាន " រ " ម្តាយឈ្មោះ ឡាយ ណៅ " រ " ។

និងចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះនាង កេត ញ៉ា អាយុ ៥០ ឆ្នាំ ជាតិ ខ្មែរ មុខរបរ ធ្វើគ្រូបង្រៀន ទីលំនៅពុ ក្រុម ២ ភូមិ រតនៈ ឃុំ រតនៈ ស្រុក ស្វាយទៀ ខេត្ត បាត់ដំបង ។ ឪពុកឈ្មោះ កេត លើម " ស " ម្តាយឈ្មោះ យូ គី " រ "

កម្មវត្ថុបណ្តឹង : ប្តឹងសុំបើកផ្លូវចេញ-ចូល ។

បានឃើញបណ្តឹងសាទុក្ខលេខ ៤៧២ ចុះថ្ងៃទី ០៨.១២.១៩៩៧ របស់ឈ្មោះសុខ ខេង ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៧៣៣ ចុះថ្ងៃទី ០៨.១២.១៩៩៧ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១៦៥ ចុះថ្ងៃទី ០៥.៦.១៩៩៨ របស់តុលាការកំពូល ។

---- ២ ----

តាមពាក្យបណ្ដឹង ចុះថ្ងៃទី ០៥.៨.១៩៨៦ អ្នកស្រី កេត ញ៉ា ប្ដឹងសុំបើកផ្លូវចេញចូលផ្ទះលើដីអ្នកស្រី សុខ ខេង ជាចុងចម្លើយ ដោយសំអាងហេតុថា: ឈ្មោះនេះបានធ្វើរបងរំលោភទៅលើផ្លូវដែលខ្លួន ធ្លាប់ដើរចេញចូលជាច្រើនឆ្នាំមកហើយ ។

បានឃើញសាលក្រមរបៀបលេខ ៩ ចុះថ្ងៃទី ៨.១១.១៩៨៦ របស់តុលាការខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :-

១- ចាត់របៀបធ្វើការអង្កេតស៊ើបសួរតាមការជូនសំអាងរបស់គូភាគី ។

២- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ១៨៧ ចុះថ្ងៃទី ០៧.០៨.៨៦ ទៅចៅក្រមអង្កេតស៊ើបសួរ ដើម្បីចាត់ការតាមច្បាប់ ។

៣- សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្ដី ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៥៤ ចុះថ្ងៃទី ១១ ខែ កម្ភៈ ឆ្នាំ ១៩៨៧ របស់តុលាការខេត្ត បាត់ដំបង សំរេចចំពោះមុខគូក្ដី ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :-

១.ក- ទទួលពាក្យបណ្ដឹង ចុះថ្ងៃទី ០៥.០៨.៨៦ របស់ដើមចោទឈ្មោះកេត ញ៉ា សុំបើកផ្លូវឆ្លងកាត់ទៅកាន់ផ្លូវសាធារណៈតាមដីចុងចម្លើយឈ្មោះ សុខ ខេង ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

ខ- ទទួលយកសំណូមពររបស់ដើមចោទ សុំបើកផ្លូវដើរតាមព្រំដីរបស់ឈ្មោះសុខខេង ជាចុងចម្លើយ ទុកជាត្រឹមត្រូវតាមគតិច្បាប់ ។

គ- បដិសេធចោលសំណូមពររបស់ចុងចម្លើយ ឈ្មោះ សុខ ខេង សុំបើកផ្លូវត្រង់ចំណុចផ្លូវចាស់នៅលើដីរបស់ខ្លួន ដោយមិនបើកផ្លូវថ្មីតាមព្រំដីខ្លួន និង ឈ្មោះ ទូច ញឹប ដោយផ្ទុយនឹងគតិច្បាប់ ។

២- បើកផ្លូវដើរ ចាប់ពីដីបិទមុខរបស់ដើមចោទ ឈ្មោះ កេត ញ៉ា កាត់តាមដីកម្មសិទ្ធិរបស់ចុងចម្លើយឈ្មោះ សុខ ខេង ចាប់ពីចំណុច J ដល់ J´ ដែលមានទទឹង ១ ម៉ែត្រ ស្របតាមព្រំដីរបស់ឈ្មោះ ទូច ញឹប ។ តាមគំនូសបង្ហាញទីតាំងដីទំនាស់ ចុះថ្ងៃទី ១៤.០៣.៨២ របស់ការិយាល័យ សុរិយោដីខេត្ត បាត់ដំបង គិតចាប់តាំងពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពរ ។

៣- អោយចុងចម្លើយឈ្មោះ សុខ ខេង រុះរើការរទាំងឡាយដែលប៉ះពាល់ដល់ការបើកផ្លូវ ចាប់តាំងពីចំណុច JJ´ ទាំងស្រុងតាមការសំរេចក្នុងចំណុចទី ២ តែអោយដើមចោទឈ្មោះ កេត ញ៉ា ចេញសំណងអន្តរាយ និង សំណូកចិត្តជាប្រាក់រៀល ចំនួន ៣៥០.០០០រៀល អោយដល់ម្ចាស់កម្មសិទ្ធិករ គឺ ចុងចម្លើយឈ្មោះ សុខ ខេង ។ គិតចាប់តាំងពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពរ។

តាមមាត្រា ១២២ , ១២៣ និង ១២៤ នៃច្បាប់ភូមិបាល ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១០០ក្រ ចុះថ្ងៃទី ១៣.១០.៨២ ។

៤- អោយចុងចម្លើយឈ្មោះ សុខ ខេង បង់ប្រាក់ប្រដាប់ក្ដី គឺ :

- ពន្ធនឹង និង ពន្ធចុះបញ្ជីក្ដី ចំនួន ១៨០០រៀល

- រង្វាន់ក្រឡាបញ្ជីការទិញទិបប្រាក់ ២០០រៀល
- ចំណាយក្នុងកិច្ចការស៊ើបអង្កេត ៥០០០រៀល

សរុប ៧.០០០រៀល

ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០រៀល ដែលដើមចោទ បានបង់រួចហើយ កាលបើប្តឹងឧទ្ធរណ៍ អោយចុងចម្លើយ សងប្រាក់ ៧.០០០រៀល ទៅដើមចោទវិញ ។

តាមច្បាប់ស្តីពី ប្រាក់ប្រដាប់ក្តី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ០៧ក្រ ចុះថ្ងៃទី ០៨.០២.៨៣ ។

៥_ សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី ។

បើកផ្លូវប្តឹងឧទ្ធរណ៍ រយៈពេល ២ខែ គិតពីថ្ងៃកាត់ក្តីតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៤០ ចុះថ្ងៃទី ០៣.៤.៨៧ របស់ឈ្មោះ សុខ ខេង ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ៥៤ ចុះថ្ងៃទី ១១.០២.១៩៨៧ របស់តុលាការខេត្ត បាត់ដំបង លើសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៧៣៣ ចុះថ្ងៃទី០៨. ១២.១៩៨៧ របស់សាលាឧទ្ធរណ៍ សំរេចចំពោះមុខគូក្តី ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១_ ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៣.៤.៨៧ របស់ឈ្មោះ សុខ ខេង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២_ តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៥៤ ចុះថ្ងៃទី ១១.០២.៨៧ របស់តុលាការខេត្ត បាត់ដំបង ទុកជាបានការដដែល ។

៣_ កាត់យកប្រាក់ប្រដាប់ក្តីនៅជាន់សាលាឧទ្ធរណ៍ ចំនួន ១៣.០០០រៀល ដែលដើមបណ្តឹងឧទ្ធរណ៍ បានបង់ទុករួច គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធតែម ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ទិបប្រាក់ ៤៥០រៀល ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ ៥.០០០រៀល និង ចំណាយលើអាផ្ទាតរតុលាការ ៥០០០រៀល សរុប ១៣.០០០រៀល ។

៤_ សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៤៧២ ចុះថ្ងៃទី ០៨.១២.១៩៨៧ របស់ឈ្មោះ សុខ ខេង ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៧៣៣ ចុះថ្ងៃទី ០៨.១២.១៩៨៧ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសារណា ចុះថ្ងៃទី ១៣.០៨.១៩៨៨ របស់ឈ្មោះ សុខ ខេង

បានឃើញសារណាតប ចុះថ្ងៃទី ១៤.១០.១៩៨៨ របស់ឈ្មោះ កេត ញ៉ា

បានស្តាប់រប្យាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ :-

សាលដីការដ្ឋប្បវេណីលេខ ៧៣៣ ចុះថ្ងៃទី ០៨.១២.៩៧ របស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាសំរេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ សុខ ខេង ជាចុងចម្លើយ និង ជាដើមបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថាៈឈ្មោះ កេត ញាំ បានប្តឹងទាមទារអោយខ្លួន បើកច្រកផ្លូវចេញចូល តាមដីកម្មសិទ្ធិរបស់ខ្លួន ស្ថិតនៅជ្រុងខាងកើត ឈៀងខាងជើង នៃដីផ្នែកខាងក្រោយផ្ទះទំហំ ៣ម គុណ ៥ ៥០ម ដើម្បីទុកលទ្ធភាពអោយគាត់ និង ក្រុមគ្រួសារ បានដើរឆ្លងកាត់ទៅតាមច្រកផ្លូវដែលបានធ្លាប់ដើរ ។តាមពិតគាត់បានសុំផ្លូវខ្លួន ដើរទេតែគាត់ហ៊ានស្បថទេថា តើផ្លូវណាដែល ដែលគាត់ធ្លាប់ដើរ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ កេត ញាំ ជាដើមចោទ និង ជាចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថាៈ ផ្លូវនេះដើរទាំង ០៣គ្រួសារ លុះក្រោយពេល ២គ្រួសារនេះឈ្លោះគ្នា គេក៏ធ្វើរបងហើយបានប្រាប់ខ្លួនថា ចែងឯដើរជាមួយគេសិនចុះ ចាំរួចរាល់ហើយចាំដើរជាមួយខ្លួនវិញ ។ លុះពេលរួចរាល់ហើយគាត់ មិនអោយខ្លួនដើរទៅវិញ ។ សំណូមពរសុំអោយផ្លូវនេះខ្លួនចេញចូល បានផង ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុ លា កា រ កំ ពូ ល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៤៧២ ចុះថ្ងៃទី ៨.១២.៩៧ របស់អ្នកស្រី សុខ ខេង ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៥ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ក៏ដូចតុលាការខេត្ត បាត់ដំបងដែរ ដែលសំរេចបើកផ្លូវអោយអ្នកស្រី កេត ញាំ កាត់តាមដីជាកម្មសិទ្ធិរបស់អ្នកស្រី សុខ ខេង នោះជាការត្រឹមត្រូវតាមមាត្រា ១២២ , ១២៣ និង ១២៤ នៃច្បាប់ភូមិបាលហើយ ហើយការសំរេចអោយបើកផ្លូវតាម ដីកាសំរេចកិច្ចការប្រញាប់របស់តុលាការខេត្ត បាត់ដំបងនោះ គ្រាន់តែជាវិធានការបណ្តោះអាសន្នប៉ុណ្ណោះ ។

- យល់ឃើញថា ការដែលអ្នកស្រី សុខ ខេង ទាមទារសំណងចិត្តរហូតដល់១០០០ដុល្លាអាមេរិកនោះតុលាការកំពូល ពុំមានសមត្ថកិច្ច ពិចារណាឡើយ ។

- យល់ឃើញថា ការដែលអ្នកស្រី សុខ ខេង សុំអោយអ្នកស្រី កេត ញាំ ស្បថនាសវនាការនេះតុលាការកំពូល ពុំមានសមត្ថកិច្ចពិចារណាឡើយ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៧៣៣ ចុះថ្ងៃទី ៨.១២.៨៧ របស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី ចំពោះមុខគូក្តី

១- ទទួលបណ្តឹងសាទុក្ខលេខ ៤៧២ ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ១៩៨៧ របស់អ្នកស្រី សុខ ខេង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ ៧៣៣ ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ១៩៨៧ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តី ចំនួន ១៩.០០០រៀល ដែលអ្នកស្រី សុខ ខេង បានបង់រួចហើយ គឺ :-

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹង ចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,

- ចំណាយក្នុងការប្រគល់ដីកាកោះចំនួន ១៥.០០០រៀលសរុប ១៩០០០រៀល។

បង្គាប់អោយអ្នកស្រី កេត ញាំ បង់ពន្ធសមាមាត្រ មួយភាគរយលើទឹកប្រាក់ ៣៥០.០០០រៀល ។